# ការបន្តយាយីតាមប្រព័ន្ធតុលាការ លើអតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី លោក យាង សុធារិន្ទ និង លោក អួន ឈិន



លោក យាង សុធារិន្ទ និង លោក អួន ឈិន គឺជាអ្នកសារព័ត៌មានឯករាជ្យ ដែលត្រូវបានបន្តរងទុក្ខបុកម្នេញ តាំងពីពេលដែលត្រូវបានចាប់ខ្លួនកាលពីឆ្នាំ២០១៧ មក។ ករណីអ្នកទាំងពីរ គឺជាករណីដែលបង្ហាញពីការយាយីតាមប្រព័ន្ធតុលាការចំពោះអ្នកសារព័ត៌មានឯករាជ្យនៅកម្ពុជា។

## អង្គហេតុករណី

អ្នកទាំងពីរធ្លាប់បម្រើការនៅវិទ្យុអាស៊ីសេរី មានការិយាល័យនៅរាជធានីភ្នំពេញ ដែលតែងតែរាយការណ៍ទាក់ទងបញ្ហាយុត្តិធម៌សង្គមនានា រហូតដល់ពេលដែលស្ថានីយវិទ្យុនេះសម្រេចចិត្តបិទការិយាល័យរបស់ខ្លួននៅកម្ពុជាក្នុងឆ្នាំ២០១៧ ក្រោមហេតុផលរងសម្ពាធនយោបាយ និងមានការយាយីចំពោះបុគ្គលិករបស់ខ្លួន។ បន្ទាប់ពីមានការបិទការិយាល័យវិទ្យុអាស៊ីសេរីមក លោក អួន ឈិន បានចាប់ផ្តើមអាជីវកម្មផលិតវីដេអូបទចម្រៀង និងវីដេអូអាពាហ៍ពិពាហ៍ ក្នុងបន្ទប់ជួលមួយនៃសណ្ឋាគារក្នុងរាជធានីភ្នំពេញ។

## ការយាយីជាបន្តបន្ទាប់

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ លោក យាង សុធារិន្ទ និងលោក អួន ឈិន ត្រូវបានចាប់ខ្លួនក្រោមការចោទប្រកាន់ថានៅតែបន្តរាយការណ៍ឱ្យវិទ្យុអាស៊ីសេរី ដោយដំណើរការបន្ទប់ផ្សាយខុសច្បាប់នៅក្នុងបន្ទប់សណ្ឋាគារមួយ។ នៅពេលចាប់ខ្លួន ប៉ូលីសមិនបានបញ្ជាក់អំពីមូលហេតុនៃការចាប់ខ្លួននោះទេ។ ក្រោយមកប៉ូលីសបានបញ្ជាក់ថាការចាប់ខ្លួនអ្នកទាំងពីរគឺដោយសារតែបើកស្ទូឌីយូខារ៉ាអូខេ ដោយមិនមានអាជ្ញាប័ណ្ណត្រឹមត្រូវ។ ដោយ យោងទៅតាមការសម្រេចជាបឋម អាជ្ញាធរបានសម្រេចស៊ើបអង្កេតករណីអ្នកទាំងពីរបន្ទាប់ពីនីតិវិធីត្រួតពិនិត្យបានរកឃើញនូវឧបករណ៍ និងសម្ភារៈថតសំឡេងនៅក្នុងបន្ទប់សណ្ឋាគារ។

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៧ សាលាដំបូងរាជធានីភ្នំពេញបានចោទប្រកាន់ជាផ្លូវការចំពោះអ្នកទាំងពីរ ពីបទ "ប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ" តាមមាត្រា ៤៤៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឬហៅម៉្យាងទៀតថាជាបទចារកម្ម ដោយត្រូវផ្តន្ទាទោសជាប់ពន្ធនាគាររហូតដល់ ១៥ឆ្នាំ។ អ្នកទាំងពីរត្រូវបានបង្គាប់ឱ្យឃុំខ្លួននៅពន្ធនាគារព្រៃសផងដែរ។

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ពេលដែលលោក យាង សុធារិន្ទ និងលោក អួន ឈិន បានជាប់ឃុំជាងបីខែ សាលាដំបូងរាជធានីភ្នំពេញ បានបន្ថែមបទចោទចំពោះអ្នកទាំងពីរ ពីបទផលិត និងកាន់កាប់រូបភាពអាសអាភាស តាមមាត្រា៣៩ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយត្រូវផ្តន្ទាទោសរហូតដល់១ឆ្នាំ។ ការចោទប្រកាន់នេះត្រូវបានធ្វើឡើងបន្ទាប់ពីរកឃើញរូបភាពរួមភេទដែលបានចេញផ្សាយមុន១ថ្ងៃ ដោយប្រព័ន្ធផ្សព្វផ្សាយដែលស្និទ្ធនឹងរដ្ឋាភិបាល។

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ អ្នកទាំងពីរត្រូវបានដោះលែង បន្ទាប់ពីជាប់ឃុំរយៈពេលជាង ៩ខែ ប៉ុន្តែនៅស្ថិតក្រោមការឃ្លាំមើលរបស់តុលាការ ដោយអ្នកទាំងពីរត្រូវបានដកហូតលិខិតឆ្លងដែន ដើម្បីធានាថាពួកគេមិនភៀសខ្លួនទៅក្រៅប្រទេស ហើយតម្រូវឱ្យបង្ហាញខ្លួននៅប៉ុស្តិ៍ប៉ូលីសជារៀងរាល់ខែ។ លោក យាង សុធារិន្ទ និងលោក អួន ឈិន បានលើកឡើងថា លក្ខខណ្ឌនៅក្រៅឃុំទាំងនេះបានរារាំងពួកគេពីការរកប្រាក់ចំណូលដើម្បីចិញ្ចឹមជីវិត។

នៅថ្ងៃទី២៦ ខែកក្កដា និងថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ សាលាដំបូងរាជធានីភ្នំពេញបានបើកសវនាការលើករណីអ្នកទាំងពីរ។ តំណាងអយ្យការ បានដេញដោលជុំវិញឯកសារដែលបានរកឃើញនៅក្នុងកុំព្យូទ័រ និងទូរស័ព្ទរបស់លោក អួន ឈិន ដោយមានសារឆ្លើយឆ្លងជាមួយមន្ត្រីទំនាក់ទំនង នៃស្ថានទូតសហរដ្ឋអាមេរិក។

នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ សាលាដំបូងរាជធានីភ្នំពេញបានខកខានក្នុងការប្រកាសសាលក្រមជាថ្មីម្តងទៀតលើបទចារកម្ម ដោយលើកមូលហេតុថាតម្រូវឱ្យធ្វើការស៊ើបអង្កេតបន្ថែមដោយសារតែគ្មានភស្តុតាងគ្រប់គ្រាន់ពាក់ព័ន្ធនឹងឧបករណ៍ផ្សព្វផ្សាយ និងខ្លឹមសារដែលមាននៅក្នុងអង្គផ្ទុកទិន្នន័យដែលបានរកឃើញ។ ប៉ុន្តែសាលាដំបូងរាជធានីភ្នំពេញមិនបានបញ្ជាក់ពីពេលវេលាក្នុងការបញ្ចប់នូវការស៊ើបអង្កេតរឿងក្តីនេះឡើយ។

លោក យាង សុធារិន្ទ និងលោក អួន ឈិន បានប្តឹងឧទ្ធរណ៍ចំពោះការស៊ើបអង្កេតជាថ្មីចំពោះបទចោទ។ នៅខែធ្នូ ឆ្នាំ២០១៩ និងខែមករា ឆ្នាំ២០២០ បន្ទាប់ពីសាលាឧទ្ធរណ៍បានបដិសេធចំពោះបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងពីរ ដោយសំអាងថាសាលាដំបូងមិនទាន់បានបញ្ចប់លើរឿងក្តីនេះទេ។ ប៉ុន្តែសាលាឧទ្ធរណ៍ មិនបានបញ្ជាក់ពីនីតិវិធីថាតើសាលាដំបូងត្រូវធ្វើអ្វីបន្តដើម្បីបញ្ចប់រឿងក្តីនេះទេ។

ការសម្រេចចិត្តរបស់តុលាការជាន់ទាប ចំពោះការស៊ើបអង្កេតឡើងវិញនូវការចោទប្រកាន់ពីបទចារកម្ម និងរូបភាពអាសអាភាស ត្រូវបានតម្កល់ទុកជាបានការដោយតុលាការកំពូលក្នុងខែកក្កដា និង ខែតុលា ឆ្នាំ២០២០។

## បច្ចុប្បន្នភាពនៃករណីអ្នកទាំងពីរ

ការចោទប្រកាន់ និងកាត់ទោសលោក យាង សុធារិន្ទ និងលោក អួន ឈិន ត្រូវបានរងការរិះគន់ពីសំណាក់អង្គការសង្គមស៊ីវិលជាតិ និងសហគមន៍អន្តរជាតិ។ នៅឆ្នាំ២០១៩ ក្រុមការងារអង្គការសហប្រជាជាតិទទួលបន្ទុកលើការឃុំខ្លួនតាមទំនើងចិត្ត បានចេញសេចក្តីថ្លែងការណ៍ចំពោះការដកហូតសេរីភាពលោក យាង សុធារិន្ទ និងលោក អួន ឈិន ថាបានបំពាននូវសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ក្រុមការងារអង្គការសហប្រជាជាតិ បានស្នើដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចាត់វិធានការចាំបាច់គ្រប់មធ្យោបាយទាំងអស់ដើម្បីដោះស្រាយករណីរបស់អ្នកសារព័ត៌មានទាំងពីររូបនេះ ដោយមិនអាចពន្យារពេលបានទៀតឡើយនូវអ្វីដែលអាជ្ញាធរកម្ពុជាខកខានមិនបានធ្វើកន្លងមក។

នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញបានបដិសេធសំណើសុំលិខិតឆ្លងដែនដើម្បីប្រើប្រាស់របស់លោក យាង សុធារិន្ទដែលស្ថិតនៅក្រោមការឃ្លាំមើលរបស់តុលាការ។ លោក យាង សុធារិន្ទ និងលោក អួន ឈិន ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមភាពមិនច្បាស់លាស់ផ្នែកផ្លូវច្បាប់អស់រយៈពេលជាង៤ឆ្នាំមកហើយ ដោយរងការគំរាមកំហែងពីបទចោទប្រកាន់ព្រហ្មទណ្ឌ និងការជាប់ពន្ធនាគាររយៈពេលវែង ទោះបីជាមិនមានភ័ស្តុតាងណាមួយជាក់លាក់ក្នុងការចោទប្រកាន់ចំពោះអ្នកទាំងពីរក៏ដោយ។

## អនុសាសន៍

ការយាយីតាមប្រព័ន្ធតុលាការដែលលោក យាង សុធារិន្ទ និងលោក អួន ឈិន បានស៊ូទ្រាំក្នុងរយៈពេលជាង ៤ ឆ្នាំចុងក្រោយនេះ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន ហើយក៏ជាឧទាហរណ៍មួយនៃការដាក់ទោសទណ្ឌ និងបំបិទសំឡេងរិះគន់នៅកម្ពុជា។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមរំលឹកថា សេរីភាពសារព័ត៌មាន គឺជាសសរស្តម្ភដ៏សំខាន់ចំពោះភាពរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យ ហើយអំពាវនាវឱ្យអាជ្ញាធរទម្លាក់ចោលរាល់ការចោទប្រកាន់ចំពោះ លោក យាង សុធារិន្ទ និងលោក អួន ឈិន ព្រមទាំងបញ្ឈប់រាល់ការយាយីតាមប្រព័ន្ធតុលាការចំពោះបុគ្គលទាំងឡាយណា ដែលអនុវត្តន៍សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មានរបស់ខ្លួនទៅលើបញ្ហានានាដែលជាប្រយោជន៍សាធារណៈ៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែមេសា ឆ្នាំ២០២២

CC BY NC SA